# យោបល់ទូទៅ ៣ (១៩៩០)

## លក្ខណៈនៃកាតព្វកិច្ចរបស់រដ្ឋភាគី
## (មាត្រា ២(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌)

១. មាត្រា ២ មានសារសំខាន់បំផុតដោយបានផ្តល់ការយល់យ៉ាងពេញលេញពីកតិកាសញ្ញា ហើយត្រូវយល់ថា មាត្រានេះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនិងបញ្ញត្តិផ្សេងៗទៀតនៃកតិកាសញ្ញានេះ។ មាត្រានេះពណ៌នាអំពីលក្ខណៈនៃកាតព្វកិច្ចនីត្យានុកូល ដែលត្រូវអនុវត្តន៍ដោយរដ្ឋជាភាគីនៃកតិកាសញ្ញានេះ។ កាតព្វកិច្ចទាំងនេះ រាប់បញ្ចូលទាំងអ្វីដែលអាចកំណត់ហៅថា (តាមការងាររបស់គណៈកម្មការច្បាប់អន្តរជាតិ) ជាកាតព្វកិច្ចក្នុងការអនុវត្តន៍ និងកាតព្វកិច្ចក្នុងការផ្តល់លទ្ធផល។ ពេលខ្លះដោយសារមានការសង្កត់ខ្លាំងទៅលើភាពខុសគ្នារវាងរូបមន្តដែលបានប្រើនៅក្នុងបទបញ្ញត្តិនេះ ហើយដែលរូបមន្តនេះមានលក្ខណៈដូចគ្នានិងមាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិង នយោបាយ តែជានិច្ចកាល គេមិនដែលទទួលស្គាល់ថាវាមានភាពស្រដៀងគ្នាជាធំដុំនោះទេ។ ជាពិសេស ទទ្ទឹមនេះ កតិកាសញ្ញាចែងពីការសំរេចបានជាលំដាប់ៗ និងទទួលស្គាល់ឧបសគ្គ ដោយសារកំរិតនៃធនធាន មាត្រានេះក៏បង្គាប់ឱ្យមានកាតព្វកិច្ចផ្សេងៗទៀត ដែលមានអានុភាពជាបន្ទាន់។ ក្នុងបណ្តាលកាតព្វកិច្ចទាំងនេះ កាតព្វកិច្ចពីរមានសារសំខាន់ខ្លាំងដើម្បីធ្វើឱ្យយល់ដឹងអំពីលក្ខណៈនៃកាតព្វកិច្ចរបស់រដ្ឋជាភាគី។ កាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចទាំងពីរនេះទាក់ទងដោយឡែកទៅនិងការពន្យល់ទូទៅ ហើយដែលនឹងត្រូវពិចារណាដោយគណៈកម្មាការ នៅក្នុងសម័យប្រជុំលើទី ៦ របស់ខ្លួននោះ គឺ " ការអនុវត្តន៍ដើម្បីធានា " ថាសិទ្ធិដែលជាប់ទាក់ទងត្រូវបានយកមកប្រតិបត្តិតាមដោយគ្មានការរើសអើង..."

២. កាតព្វកិច្ចមួយទៀតគឺការប្តេជ្ញាចិត្ត ក្នុងមាត្រា ២(១) ថា "នឹងចាត់វិធានការណ៍ផ្សេងៗ" ដែលតាមខ្លឹមសារនៃមាត្រានេះ គេមិនអាចប្រកែក ឬរិតត្បិតដោយផ្អែកលើកត្តាកំណត់ដទៃទៀតឡើយ។ អត្ថន័យទាំងមូលនៃឃ្លានេះ អាចវិនិច្ឆ័យបានដោយធ្វើការកត់សំគាល់ទៅលើការប្រើភាសាខុសៗគ្នា។ ភាសាអង់គ្លេសពាក្យប្តេជ្ញាចិត្តនេះមានន័យថា "ចាត់វិធានការណ៍" ក្នុងភាសាបារាំងមានន័យថា "ចាត់ការ" ហើយភាសាអេស្ប៉ាញ មានន័យថា "អនុម័តវិធានការណ៍"។ ដូច្នេះ ទទ្ទឹមនិងការសំរេចបានទាំងស្រុងនូវសិទ្ធិដែលពាក់ព័ន្ធអាចទទួលបានជាលំដាប់ៗ វិធានការឆ្ពោះទៅរកគោលដៅនោះត្រូវតែអនុវត្តក្នុងរយៈពេលខ្លីសមស្របបន្ទាប់ពីការចូលជាធរមាន នៃកតិកាសញ្ញាចំពោះរដ្ឋដែលពាក់ព័ន្ធ។ វិធានការទាំងនេះ ត្រូវមានលក្ខណៈជាក់ស្តែង មានបំណងនិងទិសដៅឱ្យបានច្បាស់លាស់បំផុតដែលអាចធ្វើទៅបាន ដើម្បីបំពេញតាមកាតព្វកិច្ចដែលបានទទួលស្គាល់ក្នុងកិច្ចព្រមព្រៀងនេះ។

៣. មធ្យោបាយត្រូវប្រើដើម្បីបំពេញកាតព្វកិច្ចក្នុងការចាត់វិធានការណ៍ ដូចមានចែងនៅក្នុងមាត្រា ២ (១) គឺ "រាល់មធ្យោបាយសមស្របទាំងអស់ ជាពិសេសរាប់ទាំងការអនុម័តវិធានការណ៍ខាងនីតិបញ្ញត្តិទាំងឡាយផង"។ គណៈកម្មាធិការទទួលស្គាល់ថា ក្នុងករណីខ្លះការអនុម័តច្បាប់ជាកត្តាដែលចង់បានបំផុត តែករណីខ្លះទៀត ការអនុមត្តច្បាប់កត្តាចាំបាច់បំផុត។ ឧទាហរណ៍ អាចជាការពិបាកក្នុងការប្រយុទ្ធប្រឆាំង និងអំពើរើសអើងអោយមានប្រសិទ្ធិភាព ប្រសិនបើគ្មានមូលដ្ឋានច្បាប់ល្អសំរាប់អនុវត្តវិធានការណ៍ចាំបាច់នេះទេ។ ក្នុវិស័យដូចជា សុខាភិបាល កិច្ចគាំពារកុមារ និងមាតា ការអប់រំ ព្រមទាំងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងមាត្រា ៦ ដល់ ៩ ការអនុម័តច្បាប់អាចជាកត្តាសំខាន់បំផុតសំរាប់គោលបំណងអស់ទាំងនោះ។

៤. គណៈកម្មាការកត់សំគាល់ថា រដ្ឋជាភាគីបានយកចិត្តទុកដាក់ ជាទូទៅក្នុងការបរិយាយលំអិត យ៉ាងហោចណាស់លើវិធានការណ៍ខាងនីតិបញ្ញាតិមួយចំនួន ដែលរដ្ឋជាភាគីបានអនុវត្តទាក់ទងនិងបញ្ហានេះ។ ប៉ុន្តែគណៈកម្មាការគូសបញ្ជាក់ថា ការអនុមត័វិធានការណ៍ខាងនីតិបញ្ញាតិ ដូចដែលកតិកាសញ្ញាបានប្រមាណទុកការណ៍នេះមិនបានបញ្ចប់កាតព្វកិច្ចរបស់រដ្ឋជាភាគីនោះទេ។ ម៉្យាងទៀតឃ្លាដែលចែងថា "តាមគ្រប់មធ្យោបាយសមស្របទាំងអស់" ត្រូវតែផ្តល់អត្ថន័យអោយពេញលេញនិងធម្មតា។ ទន្ទឹមនេះ រដ្ឋជាភាគីនិមួយៗ ត្រូវតែសំរេចដោយខ្លួនឯងនូវមធ្យោបាយណា១ដែលសមស្របបំផុតក្នុងកាលៈទេសៈនោះ ដែលទាក់ទិនដល់បញ្ហាសិទ្ធិនិមួយៗ ហើយ "ភាពសមប្រកប" នៃមធ្យោបាយដែលបានជ្រើសរើស ជានិច្ចកាលមិនចាំបាច់បញ្ជាក់ច្បាស់លាស់នោះទេ។ ដូច្នេះ គេចង់បានរបាយការណ៍របស់រដ្ឋជាភាគីទាំងឡាយ គម្បីចង្អុលបង្ហាញមិនត្រឹមតែវិធានការណ៍ដែលបានយកមកអនុវត្តនោះទេ តែថែមទាំងមូលហេតុនៃ "ភាពសមប្រកប" ដែលនាំអោយគេជ្រើសរើសយកវិធានការណ៍នេះសំរាប់កាលៈទេសៈនោះ។ តែទោះយ៉ាងណាដោយសេចក្តីសំរេចចុងក្រោយ ថាតើរាល់វិធានការណ៍សមស្របទាំងឡាយដែលបានអនុវត្តដោយរដ្ឋជាភាគី វាជាភារៈរបស់គណៈកម្មាការជាអ្នកសំរេច ។

៥. ក្នុងចំណោមវិធានការណ៍ដែលអាចចាត់ទុកថាសមប្រកប ក្រៅពីវិធានការណ៍ខាងផ្លូវច្បាប់ គឺការផ្តល់ការដោះស្រាយតាមផ្លូវតុលាការ ស្របតាមប្រព័ន្ធច្បាប់ជាតិ ដែលជាសិទ្ធិក្នុងការទទួលបាននូវការដោះស្រាយដោយយុត្តិធម៌។ ឧទាហរណ៍ គណៈកម្មាកាកត់សំគាល់ថា ដោយគ្មានការរើសអើង ការទទួលបានសិទ្ធិដូចដែលគេបានទទួលស្គាល់ វាចាំបាច់ត្រូវបានគេលើកកំពស់យ៉ាងសមស្រប មួយផ្នែកតាមការដំណោះស្រាយតាមផ្លូវតុលាការ ឬ ដំណោះស្រាយផ្សេងៗទៀតដែលមានប្រសិទ្ធិភាព។ តាមពិត រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ជាប់កាតព្វកិច្ចរួចជាស្រេច (តាមមាត្រា ២ (១) និង(៣) មាត្រា ៣ និង មាត្រា ២៦ នៃកតិកាសញ្ញានេះ) ក្នុងការធានាថា បុគ្គលណាដែលសិទ្ធិ ឬសេរីភាពរបស់ខ្លួន (រាប់បញ្ចូលទាំងសិទ្ធិទទួលបាននូវសមភាព និងគ្មានការរើសអើង) ដូចដែលបានទទួល

ស្គាល់ក្នុងកតិកាសញ្ញានេះ ត្រូវបានរំលោភ "ត្រូវតែមានដំណោះស្រាយដ៏មានប្រសិទ្ធិភាពមួយ" (មាត្រា ២ (៣)(ក) )។ លើសពីនេះមាន បទបញ្ញត្តិមួយចំនួនផ្សេងទៀតដែលចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ដូចជាមានមាត្រា ៣, មាត្រា ៧ (ក)(១), មាត្រា ៨, មាត្រា ១០ (៣), មាត្រា ១៣ (២)(ក), (៣) និង (៤) និងមាត្រា ១៥ (៣) ដែលបទបញ្ញត្តិទាំងនេះមានលក្ខណៈគ្រប់គ្រាន់អាចយកមកអនុវត្តបានភ្លាមតែម្តង ដោយស្ថាបន័តុលាការ និងស្ថាប័នផ្សេងទៀតនៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់ប្រទេសផ្សេងៗ។ ការយល់ណាមួយថាបទបញ្ញត្តិដែលបានចង្អុលបង្ហាញមកនេះមិនអាចយកទៅអនុវត្តដោយស្វ័យប្រវត្តិនោះ ការយល់របៀបនេះមិនត្រឹមត្រូវទេ ។

៦. ក្នុងករណីដែលមានគោលនយោបាយជាក់លាក់ក្នុងទិសដៅដើម្បីសំរេចបាននូវសិទ្ធិទាំងឡាយដូចដែលកតិកាសញ្ញាបានទទួលសាល់ ត្រូវបានអនុម័តជាទម្រង់ច្បាប់ គណៈកម្មាការចង់អោយគេផ្តល់ពត៌មានពីបញ្ហានេះទៅវិញទៅមក ថាតើច្បាប់ទាំងនេះបានបង្កើតសិទ្ធិប្តឹងតាមផ្លូវតុលាការក្នុងនាមជាបុគ្គល ឬជាក្រុម កាលណាគេបានយល់ថាសិទ្ធិរបស់ខ្លួនមិនត្រូវបានគោរពពេញលេញ ។ ក្នុងករណីដែលសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬនៅពេលដែលបទបញ្ញត្តិទាំងឡាយនៃកតិកាសញ្ញានេះត្រូវបានបញ្ចូលផ្ទាល់ទៅក្នុងច្បាប់ជាតិ គណៈកម្មាការចង់បានពត៌មាន ថាតើទំហំប៉ុណ្ណាដែលសិទ្ធិទាំងនេះត្រូវបានប្រតិបត្តិតាមដែលអាចគិតថាត្រឹមត្រូវល្អហើយ (ឧទាហរណ៏ អាចយកទៅប្រើតាមផ្លូវតុលាការ)។ គណៈកម្មាការក៏ចង់បានផងដែរនូវពត៌មានច្បាស់លាស់ស្តីពីបទបញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញដែលមានស្រាប់ ដែលធ្វើអោយរាំងស្ទះដល់ ឬត្រូវបានកែសំរួលជាដំកំភួនទាក់ទិននិងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

៧. វិធានការណ៏ផ្សេងៗទៀតដែលអាចចាត់ទុកថា "សមស្រប" តាមគោលបំណងនៃមាត្រា ២ (១) រាប់បញ្ចូលទាំង តែមិនក៏រិតត្រឹមតែ វិធានការខាងរដ្ឋបាល ខាងហិរញ្ញវត្ថុ ខាងការអប់រំ និងខាងសង្គមកិច្ចទេ ។

៨. គណៈកម្មាការកត់សំគាល់ថាការប្តេជ្ញាចិត្ត "ដើម្បីចាត់វិធានការណ៏....តាមគ្រប់មធ្យោបាយសមស្រប រាប់បញ្ចូលជាពិសេសទាំងការអនុម័តវិធានការណ៏ខាងផ្លូវច្បាប់" ឥតតម្រូវ ឬច្រានចោលនូវទំរង់នៃរដ្ឋាភិបាល ឬប្រព័ន្ធសេដ្ឋកិច្ចដែលបានប្រើរួចមកហើយជាមធ្យោបាយដើម្បីដោះស្រាយបញ្ហាជាជំហានៗ តែតម្រូវអោយមានប្រជាធិបតេយ្យ ហើយបញ្ហាសិទ្ធិមនុស្សត្រូវបានគោរព ។ ដូច្នេះ ពេលនិយាយដល់ប្រព័ន្ធនយោបាយនិងសេដ្ឋកិច្ច កតិកាសញ្ញាស្ថិតក្នុងភាពអព្យាក្រិត្យ ហើយគោលការណ៏នៃកតិកាសញ្ញាគឺមិនអាចបរិយាយត្រូវទាំងអស់បានថាវាសមនិងប្រពន្ឋ័សង្គមនិយម ឬប្រពន្ឋ័មូលធននិយម ឬប្រពន្ឋ័ចំរុះ ឬសេដ្ឋកិច្ចផែនការ ឬសេដ្ឋកិច្ចទីផ្សារសេរី ឬសមនិងប្រព័ន្ធពិសេសណាមួយឡើយ ។ ក្នុងន័យនេះ គណកម្មការបញ្ជាក់ឡើងវិញថាសិទ្ធិទាំងឡាយដែលកតិកាសញ្ញាបានទទួលស្គាល់ គឺអាចត្រូវបានធានាក្នុងបរិបទដ៏ធំទូលាយមួយនៃប្រព័ន្ធសេដ្ឋកិច្ចនិងប្រពន្ឋ័នយោបាយ ដរាបណាភាពទាក់ទងគ្នា និងមិនអាចចែកដាច់ពីគ្នានៃសិទ្ធិទាំងពីរផ្នែក

ដូចចែងនៅក្នុងបុព្វកថានៃកតិកាសញ្ញា គឺត្រូវបានគេទទួលស្គាល់ហើយចែងឡើងនៅក្នុងប្រព័ន្ធដែលស្ដីមកនេះ។ គណៈកម្មាការក៏បានកត់សំគាល់សពីបណ្ដាលសិទ្ធិមនុស្សឯទៀតៗ ជាពិសេសគឺសិទ្ធិក្នុងការអភិវឌ្ឍន៍។

៩. កាតព្វកិច្ចចំបងក្នុងការផ្ដល់លទ្ធផល ដូចមានចែងក្នុងមាត្រា ២ (១) គឺត្រូវចាត់វិធានការណ៍ "ក្នុងទិសដៅដើម្បីធ្វើឱ្យសំរេចបានជាបន្តបន្ទាប់នូវការទទួលបានសិទ្ធិទាំងឡាយដូចដែលបានទទួលស្គាល់" ក្នុងកតិកាសញ្ញា។ ពាក្យថា "ការសំរេចបានជាលំដាប់" ជាញឹកញយតូវបានគេប្រើដើម្បីពណ៌នាពីបំណងនៃប្រយោគ។ តំណើរនៃការសំរេចបានជាលំដាប់ តាមពិតគេទទួលស្គាល់ថា ការសំរេចបានទាំងស្រុងនូវសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធមិ ជាទូទៅមិនអាចសំរេចបានក្នុងរយៈពេលខ្លីទេ។ តាមន័យនេះ កាតព្វកិច្ចនេះខុសគ្នាឆ្ងាយពីកាតព្វកិច្ចដែលចែងក្នុងមាត្រា ២ នៃកតិកាសញ្ញអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលតម្រូវអោយមានកាតព្វកិច្ចភ្លាមៗ ដើម្បីគោរពនិងធានារ៉ាប់រងលើគ្រប់បណ្ដាលសិទ្ធីដែលទាក់ទិន។ យ៉ាងណាក៏ដោយ មូលហេតុស្ដីពីការសំរេចបានក្នុងរយៈពេលយូរ ឬក្នុងន័យម៉្យាងទៀតថាជាការសំរេចបានជាលំដាប់ ដូចកតិកាសញ្ញាបានប្រមាណទុក មិនត្រូវបកស្រាយខុសថាជាការដកកាតព្វកិច្ចនោះទេ។ ករណីចាំបាច់វាអាចផ្លាស់ប្ដូរទៅតាមកាលៈទេសៈ ដោយយោងទៅតាមភាពជាក់ស្ដែងក្នុងពិភពលោក និងភាពលំបាករបស់ប្រទេសណាមួយក្នុងការធានារ៉ាប់រងនូការសំរេចបានទាំងស្រុងនូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធិម។ ម៉្យាងទៀត ឃ្លានេះត្រូវតែបកស្រាយតាមគោលបំណងទូទៅ តាមពិតគឺទៅតាមមូលហេតុដែលនាំអោយមានកតិកាសញ្ញានេះឡើង ហើយហេតុផលគឺដើម្បីបង្កើតកាតព្វកិច្ចមួយជាក់លាក់ទៅអោយរដ្ឋជាភាគីទាក់ទិននិងការធ្វើឱ្យសំរេចបានទាំងស្រុងនូវសិទ្ធិទាំងឡាយនេះ។ ដូច្នេះ កតិកាសញ្ញា ដាក់កាតព្វកិច្ចឱ្យរដ្ឋជាភាគីអនុវត្តឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធិភាពតាមដែលអាចធ្វើទៅបានដើម្បីសំរេចគោលដៅនេះ។ ម្យ៉ាងវិញទៀត រាល់វិធានការណ៏អន់ថយណាមួយដែលគ្រោងទុក ការអនុវត្តដូច្នេះតម្រូវឱ្យមានការពិចារណាដោយប្រុងប្រយ័ត្នបំផុត និងត្រូវមានហេតុផលសមស្របគ្រប់គ្រាន់ ដោយគិតទាំងស្រុងទៅដល់សិទ្ធិទាំងឡាយដែលមានចែងក្នុងកតិកាសញ្ញា និងក្នុងទំហំនៃការប្រើប្រាស់នូវធនធានអតិបរិមាដែលមាន។

១០. ផ្អែកតាមបទពិសោធន៏ទូលំទូលាយដែលគណៈកម្មាការបានទទួល ដូចគ្នានិងបទពិសោធន៏មុនៗ ដែលអង្គការទទួលបាន ក្នុងរយៈពេលជាងមួយទសវត្សន៏ក្នុងការពិនិត្យបាយការណ៏របស់រដ្ឋជាភាភាគី គណៈកម្មាការមានទស្សនៈថា រដ្ឋជាភាគីនីមួយៗមានកាតពព្វកិច្ចសំខាន់ជាអប្បបរិមា ដើម្បីធានារ៉ាប់រងនូវការបំពេញបានយ៉ាងហោចណាស់នូវក៏រិតសំខាន់អប្បរិមានៃសិទ្ធិនីមួយៗ។ ឧទាហរណ៏ ក្នុងរដ្ឋជាភាគី បើមានមនុស្សមួយចំនួនធំខ្វះខាតយ៉ាងខ្លាំងនូវ ចំណីអាហារ ការថែទាំសុខភាពបឋម ទីជម្រកនិងផ្ទះសំម្បែង ឬមិនមានការអប់រំជាមូលដ្ឋាន ការណ៏នេះជាភស្តុតាងជាក់ស្ដែងនៃការខកខានមិនបានអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងកតិកាសញ្ញា។ ការបកស្រាយណាមួយថាកតិកាសញ្ញានេះមិនបានបង្កើតកាតព្វកិច្ចសំខាន់ជាអប្បបរិមាទេនោះ ការយល់បែបនេះនឹងនាំអោយបាត់នូវមូលហេតុដែលនាំអោយមានកតិកាសញ្ញនេះ។ ដូចគ្នាដែរ

គម្បីកត់សំគាល់ថា ដើម្បីវាយតម្លៃថា តើរដ្ឋជាភាគីបានបំពេញកាតព្វកិច្ចសំខាន់ជាអប្បបរិមា ឬយ៉ាងណានោះ គម្បីត្រូវគិតដល់កំហិតធនធានដែលមានក្នុងប្រទេសនោះ។ មាត្រា ២ (១) បង្គាប់ឱ្យរដ្ឋជាភាគីនិមួយៗ ចាត់វិធានការណ៍ចាំបាច់ " ឱ្យបានដល់កំរិតអតិបរិមានៃធនធានរបស់ខ្លួនដែលមាន " ។ ដើម្បីឱ្យរដ្ឋជាភាគីណាមួយអាចលើកមូលហេតុខ្វះធនធានមកដោះសារ កាលបើមិនបានបំពេញកាតព្វកិច្ចស្នូលអប្បបរិមារបស់ខ្លួន រដ្ឋជាភាគីត្រូវតែបញ្ជាក់ថា ខ្លួនបានខំប្រឹងប្រែងអស់វិធីក្នុងការប្រើធនធានទាំងអស់ដែលខ្លួនមាន ដើម្បីបំពេញកាតព្វកិច្ចស្នូលអប្បបរិមាទាំងនោះទៅតាមអាទិភាព។

១១. តែទោះយ៉ាងណា គណៈកម្មាការចង់បញ្ជាក់ថា ទោះបីជាធនធានដែលមាននោះ ត្រូវបានបង្ហាញឱ្យឃើញថាមានមិនគ្រប់គ្រាន់ក្តី រដ្ឋជាភាគីត្រូវតែព្យាយាមដើម្បីធានាអោយបាននូវការប្រើប្រាស់សិទ្ធិដែលពាក់ពន្ធ័ឱ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបានក្នុងកាលៈទេសៈនោះ។ ម្យ៉ាងវិញទៀត ការខ្វះខាតធនធានមិនលុបចោលនូវកាតព្វកិច្ចត្រួតពិនិត្យលើទំហំនៃការសំរេចបាន ឬការមិនទាន់សំរេចបាននូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយការខ្វះធនធានក៏មិនបានលុបចោលនូវកាតព្វកិច្ចក្នុងការបង្កើតយុទ្ធសាស្ត្រនិងកម្មវិធីសម្រាប់លើកស្ទួយសិទ្ធិទាំងឡាយនេះដែរ។ គណៈម្មាការបាននិយាយរួចមកហើយលើបញ្ហាទាំងនេះក្នុងយោបល់ទូទៅលេខ ១ (១៩៨៩)។

១២. ដូចគ្នានេះដែរ គណៈកម្មាការបានគូសបញ្ជាក់មូលហេតុថា ទោះជាស្ថិតក្នុងពេលមានកង្វះធនធានធ្ងន់ធ្ងរបណ្តាលមកពីការបំរែបំរួល ការស្រុតចុះនៃសេដ្ឋកិច្ច ឬដោយកត្តាផ្សេងៗទៀតក្តី សមាជិកក្នុងសង្គមដែលទន់ខ្សោយអាចហើយត្រូវតែទទួលបានការពារតាមរយៈការអនុវត្តកម្មវិធីដែលចំណាយតិច។ ដើម្បីជាបង្អែកក្នុងការអនុវត្តដូចនេះ គណៈកម្មាកាលើកឡើងនូវការវិភាគរបស់ UNICEF ដែលមានចំណងជើងថា "ការកែតម្រូវដើម្បីគោរពនូវតម្លៃជាមនុស្ស : ការការពារដល់ជនទន់ខ្សោយ និងការជំរុញកិច្ចអភិវឌ្ឍន៍" ការវិភាគរបស់ UNDP ក្នុងរបាយការណ៍របស់ខ្លួនស្តីពីការអភិវឌ្ឍន៍មនុស្សឆ្នាំ ១៩៩០ និងការវិភាគរបស់ធានាគារពិភពលោក ក្នុងរបាយការណ៍ស្តីពីការអភិវឌ្ឍន៍ពិភពលោកឆ្នាំ ១៩៩០។

១៣. ចំណុចចុងក្រោយមួយនៃមាត្រា ២ (១) ដែលត្រូវយកចិត្តទុកដាក់នោះ គឺថារដ្ឋជាភាគីនិមួយៗបានសន្យា "ចាត់គ្រប់វិធានការណ៍ដោយខ្លួនឯង តាមរយៈជំនួយអន្តរជាតិផង និងតាមបែបសហប្រតិបត្តិការផងជាពិសេសគឺក្នុងវិស័យសេដ្ឋកិច្ច និងបច្ចេកទេស.....។ គណៈកម្មាការគូសបញ្ជាក់លើឃ្លាថា "ធនធានអតិបរិមាដែលមាន" គឺអ្នកព្រាងកតិកាសញ្ញាមានបំណងសំដៅយកទាំងធនធានផ្ទាល់របស់រដ្ឋ និងធនធានទទួលបានពីសហគន៏អន្តរជាតិតាមរយៈជំនួយអន្តរជាតិ និងការសហប្រតិបត្តិការ។ លើសពីនេះ ខចែងក្នុងមាត្រា ១១, ១៥, ២២ និង ២៣ សង្កត់លើតួនាទីយ៉ាងសំខាន់នៃកិច្ចសហប្រតិបត្តិការផងដែរ ពេលនិយាយដល់ការសំរេចបានពេញលេញនូវសិទ្ធិដែលជាប់ទាក់ទង។ ចំពោះមាត្រា ២២ គណៈកម្មាការបានសង្កត់រួចមកហើយ

ក្នុងយោបល់ទូទៅលេខ ២ (១៩៩០) ស្តីពីឱកាស និងការទទួលខុសត្រូវនានាដែលមានទាក់ទងនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ចំណែកឯ មាត្រា ២៣ បាននិយាយច្បាស់ពី "ការផ្តល់ជំនួយបច្ចេកទេស" ព្រមទាំងសកម្មភាពដទៃទៀតក្នុងចំណោម "សកម្មភាពអន្តរជាតិ ដើម្បីសំរេចបាននូវសិទ្ធិទាំងឡាយដែលបានទទួលស្គាល់........"។

១៤. គណៈកម្មាការចង់បញ្ជាក់ថា ស្របតាមមាត្រា ៥៥ និង៥៦ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ស្របតាមគោលការណ៍គ្រឹះនៃច្បាប់អន្តរជាតិ និងស្របតាមបទបញ្ញត្តិមួយចំនួននៃកតិកាសញ្ញានេះ កិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីអភិវឌ្ឍន៍ និងដើម្បីសំរេចបាននូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គឺជាកាតព្វកិច្ចមួយរបស់រដ្ឋទាំងអស់។ ជាពិសេស កាតព្វកិច្ចនេះត្រូវធ្លាក់ទៅលើរដ្ឋទាំងឡាយណាដែលស្ថិតក្នុងស្ថានភាពជាអ្នកជួយរដ្ឋដទៃទៀតចំពោះបញ្ហានេះ។ គណៈកម្មាការគូសបញ្ជាក់ជាពិសេសទៅលើសារៈសំខាន់នៃសេចក្តីប្រកាសស្តីពីសិទ្ធិទទួលការអភិវឌ្ឍន៍ដែលបានអនុម័តក្នុងមហាសន្និបាតតាមសេចក្តីសំរេចលេខ ៤/១២៨ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ១៩៨៦ និងតម្រូវការដើម្បីឱ្យរដ្ឋជាភាគីទាំងឡាយពិចារណាអោយបានពេញលេញលើគោលការណ៍ទាំងអស់ដូចបានទទួលស្គាល់នៅក្នុងសេចក្តីប្រកាស។ គណៈកម្មាការលើកឡើងថា បើបណ្តាលរដ្ឋដែលស្ថិតក្នុងស្ថានភាពជាអ្នកជួយ ហើយមិនបានអនុវត្តនូវកម្មវិធីសហប្រតិបត្តិការអន្តរជាតិ និងជំនួយអន្តរជាតិយ៉ាងសកម្មទេនោះ ដូចេះការសំរេចបានពេញលេញនូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នឹងនៅជាសេចក្តីប្រាថ្នាដែលមិនទាន់សំរេចបាន ។ ក្នុងន័យនេះ គណៈកម្មាការក៏រំលឹកឡើងវិញនូវខ្លឹមសារនៅក្នុងយោបល់ទូទៅរបស់ខ្លួនលេខ ២ (១៩៩០) ។